BỘ TƯ PHÁP | CHÍNH PHỦ NHẬT BẢN | QUỸ PHÁT TRIỂN XÃ HỘI NHẬT BẢN | NGÂN HÀNG THẾ GIỚI

ជំនួយគតិយុត្តិស្តីពីការប្រគល់កូន និងការផ្តត់ផ្តង់ចិញ្ចឹមកូនពេលលែងលះ



ឆ្នាំ ២០២៥.

តើជំនួយគតិយុត្តិជាអ្វី?

ជំនួយគតិយុត្តិ គឺជាការផ្តល់សេវាគតិយុត្តិដោយឥតគិតថ្លៃ ជូនអ្នកទទួលបានជំនួយគតិយុត្តិ ក្នុងរឿងក្តីជំនួយគតិយុត្តិ ស្រប តាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីជំនួយគតិយុត្តិ។

អ្នកដែលស្ថិតក្នុងចំណោមអ្នកទទួលបានជំនួយគតិយុត្តិ រួមមាន៖

- អ្នកមានគុណបំណាច់ចំពោះបដិវត្តន៍។
- អ្នកស្ថិតក្នុងគ្រួសារក្រីក្រ។
- កុមារ។
- ជនជាតិភាគតិចដែលរស់នៅតំបន់មានលក្ខខណ្ឌសេដ្ឋកិច្ច-សង្គមលំបាកជាពិសេស។
- អ្នកមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ៖ គឺជាអ្នកត្រូវបានចោទប្រកាន់ អ្នកត្រូវបានស្នើសុំឲ្យចោទប្រកាន់ អ្នកត្រូវបានឃាត់ខ្លួនក្នុងករណីបន្ទាន់ អ្នកជាប់ចោទ ជនរងគ្រោះ សាក្សី អ្នកអនុវត្តវិធានការដោះស្រាយបែបបង្វែរទិស និងទណ្ឌិត (អនុវត្តចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០២៦)។
- អ្នកចុងចោទដែលស្ថិតក្នុងគ្រួសារបៀតក្រីក្រ។
- ជនរងគ្រោះ អ្នកកំពុងស្ថិតក្នុងដំណើរការបញ្ជាក់ថាជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងអ្នកអាយុក្រោម ១៨ ឆ្នាំដែលទៅជាមួយ ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការទប់ស្កាត់ និងប្រឆាំងការជួញដូរមនុស្ស។
- អ្នកស្ថិតក្នុងករណីណាមួយដូចខាងក្រោម ដែលមានការលំបាកផ្នែកហិរញ្ញវត្ថុ៖
- ឪពុកបង្កើត ម្តាយបង្កើត ភរិយា ស្វាមី កូនរបស់យុទ្ធជនពលី និងអ្នកមានគុណបំណាច់ចិញ្ចឹមបីបាច់យុទ្ធជនពលីកាលនៅតូច។
- អ្នកឆ្លងជាតិពុលពណ៌ទឹកក្រូច (ដាយអុកស៊ីន)។
- មនុស្សចាស់។
- ជនពិការ។
- អ្នកមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ដែលជាជនរងគ្រោះក្នុងរឿងក្តីព្រហ្មទណ្ឌ។
- ជនរងគ្រោះក្នុងរឿងក្តីអំពើហិង្សាក្នុងគ្រួសារ។
- អ្នកផ្ទុកមេរោគអេដស៍ (HIV)។



- ពាក្យស្នើសុំជំនួយគតិយុត្តិ (តាមទម្រង់លេខ 02-TP-TGPL ដែលចេញផ្សាយភ្ជាប់ជាមួយសារាចរណែនាំលេខ 12/2018/TT-BTP)។
- លិខិតស្នាមបញ្ជាក់ថាជាអ្នកទទួលបានជំនួយគតិយុត្តិ (មាត្រា ៣៣ នៃសារាចរណែនាំលេខ 08/2017/TT-BTP)។
- លិខិតស្នាម និងឯកសារនានាដែលពាក់ព័ន្ធនឹងរឿងក្តី។

អាសយដ្ឋានទំនាក់ទំនងដើម្បីស្នើសុំជំនួយគតិយុត្តិ៖

- មជ្ឈមណ្ឌលជំនួយគតិយុត្តិរបស់រដ្ឋ ក្រោមឱវាទមន្ទីរយុត្តិធម៌ខេត្ត និងក្រុង ក្រោមឱវាទថ្នាក់កណ្តាល។
- អង្គការប្រកបវិជ្ជាជីវៈមេធាវី និងអង្គការប្រឹក្សាច្បាប់ ដែលចូលរួមជំនួយគតិយុត្តិ។
- អាសយដ្ឋានរបស់អង្គការអនុវត្តជំនួយគតិយុត្តិដែលបានរៀបរាប់ខាងលើ ត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅ៖
- គេហទំព័រនីតិកម្មជាតិ *(https://phapluat.gov.vn/)*
- គេហទំព័រព័ត៌មានអេឡិចត្រូនិកក្រសួងយុត្តិធម៌ *(https://dstrogiupphaply.moj.gov.vn/all/searchOrganization)*។
- គេហទំព័រព័ត៌មានអេឡិចត្រូនិកជំនួយគតិយុត្តិវៀតណាម *(https://tgpl.moj.gov.vn/Pages/danh-ba-phap-ly.aspx)*។
- គេហទំព័រព័ត៌មានអេឡិចត្រូនិកមន្ទីរយុត្តិធម៌។
- លោកអ្នកអាចទាក់ទងតាមបណ្តាញដូចខាងក្រោម ដើម្បីដឹងព័ត៌មានបន្ថែមអំពីជំនួយគតិយុត្តិ៖
- ខ្សែទូរស័ព្ទទាន់ហេតុការណ៍អំពីជំនួយគតិយុត្តិ៖ *18001233/02462739631*
- ទាញយកកម្មវិធីទូរស័ព្ទចល័តអំពីជំនួយគតិយុត្តិ។

ពេលលែងលះ ភរិយា និងស្វាមី ព្រមព្រៀងគ្នា
(ប្រការ ២ មាត្រា ៨១ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ)

សិទ្ធិ និងករណីយកិច្ចរបស់ភាគីនីមួយៗ ចំពោះកូន។

អ្នកចិញ្ចឹមកូនផ្ទាល់។

បើមិនអាចព្រមព្រៀងគ្នាបាន តុលាការនឹងប្រគល់កូនឲ្យភាគីម្ខាងចិញ្ចឹមផ្ទាល់ ដោយផ្អែកលើ៖

ផលប្រយោជន៍គ្រប់ផ្នែករបស់កូន

កូនអាយុក្រោម ៣៦ ខែ ត្រូវប្រគល់ឲ្យម្តាយចិញ្ចឹមផ្ទាល់ លើកលែងតែករណីម្តាយគ្មានលក្ខខណ្ឌគ្រប់គ្រាន់ក្នុងការមើលថែ ថែរក្សា ចិញ្ចឹមបីបាច់ និងអប់រំកូនផ្ទាល់ ឬឪពុកម្តាយមានកិច្ចព្រមព្រៀងផ្សេងទៀតដែលសមស្របនឹងផលប្រយោជន៍របស់កូន។

- សេចក្តីប្រាថ្នារបស់កូន បើកូនមានអាយុ ០៧ ឆ្នាំឡើងទៅ។



ផលប្រយោជន៍គ្រប់ផ្នែករបស់កូន រួមមាន៖

- លក្ខខណ្ឌ និងសមត្ថភាពរបស់ឪពុកម្តាយ ក្នុងការមើលថែ ថែរក្សា ចិញ្ចឹមបីបាច់ និងអប់រំកូន រួមទាំងសមត្ថភាពការពារកូនពីការបំពាន និងការកេងប្រវ័ញ្ច។
- សិទ្ធិរបស់កូនក្នុងការរស់នៅជាមួយអ្នកចិញ្ចឹមផ្ទាល់ និងក្នុងការរក្សាទំនាក់ទំនងជាមួយឪពុក ឬម្តាយដែលមិនចិញ្ចឹមផ្ទាល់។
- ភាពស្និទ្ធស្នាល និងជិតស្និទ្ធរបស់កូនជាមួយឪពុកម្តាយ។
- ការយកចិត្តទុកដាក់របស់ឪពុកម្តាយចំពោះកូន។
- ធានាភាពនឹងនរ និងកាត់បន្ថយការប្រែប្រួលបរិស្ថានរស់នៅ និងការសិក្សាអប់រំរបស់កូន។
- សេចក្តីប្រាថ្នារបស់កូនក្នុងការនៅជាមួយបងប្អូន (បើមាន) ដើម្បីធានាស្ថិរភាពផ្លូវចិត្ត និងអារម្មណ៍របស់កូន។
- សេចក្តីប្រាថ្នារបស់កូនក្នុងការរស់នៅជាមួយឪពុក ឬម្តាយ។

សិទ្ធិ និងករណីយកិច្ចក្រោយពេលប្រគល់កូន (មាត្រា ៨១ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ)

* អ្នកមិនចិញ្ចឹមកូនផ្ទាល់៖

- គោរពសិទ្ធិរបស់កូនក្នុងការរស់នៅជាមួយអ្នកចិញ្ចឹមផ្ទាល់។
- មានករណីយកិច្ចផ្តត់ផ្គង់ចិញ្ចឹមកូន។
- មានសិទ្ធិទៅសួរសុខទុក្ខកូន ដោយគ្មាននរណាម្នាក់អាចរារាំងបានឡើយ។

* អ្នកចិញ្ចឹមកូនផ្ទាល់៖

- មានសិទ្ធិស្នើសុំឲ្យអ្នកមិនចិញ្ចឹមកូនផ្ទាល់ អនុវត្តករណីយកិច្ចនានាតាមបទប្បញ្ញត្តិនៅមាត្រា ៨២ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ។ ស្នើសុំឲ្យអ្នកមិនចិញ្ចឹមកូនផ្ទាល់ ព្រមទាំងសមាជិកគ្រួសារ គោរពសិទ្ធិចិញ្ចឹមកូនរបស់ខ្លួន។
- មិនត្រូវរារាំងអ្នកមិនចិញ្ចឹមកូនផ្ទាល់ ក្នុងការទៅសួរសុខទុក្ខ ថែរក្សា ចិញ្ចឹមបីបាច់ និងអប់រំកូនឡើយ។

ការផ្តត់ផ្គង់ចិញ្ចឹមកូន
(មាត្រា ៨២ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ)

ភាគីមិនចិញ្ចឹមកូនផ្ទាល់ មានករណីយកិច្ចផ្តត់ផ្គង់ចិញ្ចឹមកូន រហូតដល់កូនមានអាយុពេញ ១៨ ឆ្នាំ (ឬកូនអាយុលើសពី ១៨ ឆ្នាំ តែបាត់បង់លទ្ធភាពការងារ គ្មានទ្រព្យសម្បត្តិចិញ្ចឹមខ្លួនឯង)។

- **កម្រិតផ្តត់ផ្គង់៖ ព្រមព្រៀងគ្នា បើមិនបានទេ តុលាការនឹងសម្រេចដោយផ្អែកលើចំណូល សមត្ថភាពជាក់ស្តែងរបស់អ្នកផ្តត់ផ្គង់ និងតម្រូវការរបស់កូន។**
- **រយៈពេល៖ ការផ្តត់ផ្គង់អាចធ្វើតាមកាលកំណត់ជារៀងរាល់ខែ។ តាមលើក ត្រីមាស ឆ្នាំ ឬម្តងអស់ (បើមានលក្ខខណ្ឌ និងភាពងាយស្រួល) ឬដោយប្រាក់ ទ្រព្យសម្បត្តិ ឬទម្រង់ផ្សេងទៀតដែលសមស្រប។**